# ព្រះពុទ្ធសាសនាដូចម្ដេច?

រៀបរៀងដោយ

## ព្រះវីរិយបណ្ឌិតោ ប៉ាង-ខាត់




**វត្តឧណ្ណាលោម ភ្នំពេញ**

**ព.ស. ២៥១៤** **គ.ស. ១៩៧០**



# បុព្វកថា

## របស់អ្នកវាយអក្សរកុំព្យូទ័រ

សៀវភៅ **“ពុទ្ធសាសនាដូចម្ដេច?”** ជាស្នាព្រះហស្តរបស់ព្រះតេជគុណព្រះមហាវិរិយបណ្ឌិតោ **ហ្វ៊ាង-ខាត់** ដែលលោកបានសរសេរកាលពីឆ្នាំ១៩៧០ ។

សៀវភៅ **“ពុទ្ធសាសនាដូចម្ដេច?”** បានបោះពុម្ពផ្សាយដោយ លោក ឱក-គាម និង ភរិយា ចំនួន៥០០ក្បាល និងរោងពុម្ព វត្តភ្នំ ចំនួន៥០០ក្បាលដែរ ដើម្បីចែកជាធម្មទាន ជូនសាធារណជន ក្នុងឱកាសបុណ្យព្រះបរមសពព្រះសង្ឃរាជគណៈមហានិកាយ **ជួន-ណាត** ដែលទ្រង់សោយទិវង្គតកាលពីថ្ងៃទី២៥ កញ្ញា ១៩៦៩ ។

បានន័យថា សៀវភៅ**“ពុទ្ធសាសនាដូចម្ដេច?”**នេះ បានបោះពុម្ពផ្សាយតែ១០០០ក្បាលប៉ុណ្ណោះ ឃើញថាការផ្សព្វផ្សាយបានតិចតួចណាស់ ។

ដោយខ្ញុំមានសៀវភៅ **“ពុទ្ធសាសនាដូចម្ដេច?”** មួយក្បាលដែលចាស់ ទក់ រហែកខ្លះ តែអាចនៅអានបាន ហើយដោយយល់ឃើញថា សៀភៅនេះមានអត្ថន័យ អត្ថរសជ្រាលជ្រៅ និងមានសារៈប្រយោជន៍ខ្ពង់ខ្ពស់សំរាប់កូនខ្មែរជំនាន់ក្រោយក្នុងការចង់ចេះចង់ដឹងអំពីព្រះពុទ្ធសាសនា ខ្ញុំក៏វាយអក្សរកុំព្យូទ័រឡើងវិញ ដោយរក្សាភាពដើមរបស់អ្នកនិពន្ធ ដើម្បីចែកជូនសាធារណជនខ្មែរបានអានផង ។

ខ្ញុំសូមឧទ្ទិសកុសលនេះ ប្រគេនព្រះវិញ្ញាណក្ខន្ធ ព្រះតេជគុណព្រះវិរិយបណ្ឌិតោ **ហ្វ៊ាង-ខាត់** ដែលជាម្ចាស់សៀវភៅ និងជាព្រះសង្ឃគំរូ ជាទីគោរពនៃខ្ញុំ , សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ **ជួន-ណាត** ជោតញ្ញាណោ, ព្រះគ្រូធម្មឃោសាចារ្យ **សេក-នាង** និងព្រះគ្រូ **ទេព-ផ្វូត** ហៅផុន ដែលទាំង២ព្រះអង្គជាគ្រូបង្រៀនរបស់ខ្ញុំ ផ្នែកព្រះពុទ្ធសាសនា ។ ព្រមទាំងឧទ្ទិសជូន បុព្វការីជនទាំងឡាយ មានមាតាបិតារបស់ខ្ញុំ សូមលោកអ្នកដ៏មានគុណទាំងឡាយនោះ បានសម្រេចក្នុង សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃទី ២១ ឧសភា ២០០៩

សំ-វិជ្ជា

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

អ្នកមេគិត (Grands Penseurs) ទាំងអស់ បានធ្វើការពិសោធន៍ពីលទ្ធិសាសនា ពិសោធ ហើយ ពោលអះអាងថាមាន "**អាទិទេព**" (Dieu) ជាមហេស្វរ "មហាទេពជាកំពូល" ឬ ប្រជាបតិ "ម្ចាស់សព្វសត្វ" ។ គំនិតបែបនេះ មាននៅក្នុងគម្ពីរលទ្ធិសាសនា មានគម្ពីរវេទ (ឧបនិបទ) និងសៀវភៅជាស្នាដៃលោក**ប្លាតុង** (Platon) **អារិស្តូត** (Aristote) ជាដើម ។ នៅក្នុងសៀវភៅ **សាំងតូម៉ាសដាកាំង** (Saint Thomas D'Aquin) មានសេចក្តីថា "បានពិសោធឃើញថា មានអាទិទេពហើយ" ដែរ ។

ទស្សនវិទូ ដូចលោក **កង់** (Kant) បញ្ចេញទ្រឹស្តីថា "ជំនឿដែលជឿស៊ប់ថាមានអាទីទេព តែងតែមានកើតនៅក្នុងសន្តានចិត្តមនុស្សទូទៅ" ។ លោក **ហេគេល** (Hegel) ស្ដីទុកថា "គំនិតដែលជឿថាមានអាទិទេពនេះ កើតមានឡើង ក៏កើតដោយសារតែមានវិជ្ជាដែលជារបស់មនុស្សនេះឡើង" ។ រីលោក **មហាត្មគន្ធិ** លោកចូលចិត្តមានប្រសាសន៍ថា **"សច្ចធម៌ជាអាទិទេព"** តែ **"អាទិទេពពុំមែនជាសច្ចធម៌ទេ"** (Truth is god and not is truth) ។

ដូច្នេះ លទ្ធិសាសនាទាំងអស់ ឬ ពាហិរសាសនា (Religions) ជាមេនាំអាទិធ្វើឲ្យមានជំនឿថាមាន "**អាទិទេព**" ហើយអាទិទេពនេះ មិនគឺអ្វីដទៃទេគឺ "**សច្ចធម៌**" នេះឯង (God is truth) ពោលគឺ អាទិទេពនេះជា "ភាវៈនៃសច្ចធម៌ = សត្យស្វរូប" ។ សេចក្ដីនេះ បើនិយាយឲ្យងាយយល់ យើងគួរនិយាយថា "អ្នកមេគិតទាំងអស់ បានគន់គិតរកថាអ្វីជាសេចក្ដីពិត = សច្ចធម៌" រកទៅឃើញតាមគំនិតរបស់ខ្លួន ហើយបញ្ញត្តនាមតាមភាសារបស់ខ្លួន បើជាហិណ្ឌូថា ទេវៈ "ទេពតា" បើជាអ្នកបស្ចិមថា Dieu "អាទិទេព" បើជាចិនថា តៅ "សភាវធម៌" តមក ក្នុងកាលជាខាងក្រោយ នាមទាំងនេះ កើតបានជាបញ្ញត្តសព្ទ (Concept) ជាប់ក្នុងសន្តានចិត្ត ហើយមានជំនឿឥតហេតុផល (Foi, croyance) នៅកើតឡើង ទើបប្រកាន់យកទិដ្ឋិ (Dogme) របស់ខ្លួន ។ ព្រះយេស៊ូគ្រិស្ដ (Jesus Christ) សម្ដែងទុកថា "សច្ចធម៌មាននៅក្នុងខ្លួនយើង ហើយធ្វើឲ្យខ្លួនយើងមានសេរីភាព" ។ ឯពាក្យដែលព្រះយេស៊ូទេសនាទុកថា "ចូរស្នេហាចំពោះព្រះអាទិទេពឲ្យអស់ពីចិត្ត" នោះ បានសេចក្ដីថា "ចូរស្នេហាព្រះអាទិទេពដោយប្រាជ្ញាជាធម៌សំខាន់ដែលមាននៅក្នុងខ្លួនមនុស្សលោក" ។

សេចក្ដីពិត ដើមឡើយ គម្ពីរឫគ្វេទបានបញ្ជាក់ថា ធម្មជាតិ គឺ ទឹក-ដី-ភ្លើង-ខ្យល់ ជាវត្ថុធាតុដើម ដែលជនហិណ្ឌូយល់ថា ញ៉ាំងជីវិតខ្លួនឲ្យរស់នៅបាន ទើបគេនាមថាជា "ទេវៈ = ទេវតា" មិនគឺអ្វីដទៃទេ ។ តមក ក្នុងកាលជាខាងក្រោយ អស់កាលយូរច្រើនសតវត្សរ៍ ទើបពាក្យថា "ទេវៈ" នេះឯង រីកសាយន័យ ហើយកើតបានទៅជា "មហេស្វរ ឬ ប្រជាបតិ"(Dieu) ទៅតាមសភាវគតិជាធម្មតាមនុស្សលោក ។ សព្វថ្ងៃនេះ ពាក្យថា "ទេវៈ" ដែលគ្រាន់តែជាតួបុគ្គលាធិដ្ឋាន ឬជាបញ្ញត្តសព្ទ(Concept) នេះ កើតជាឧបក្កិលេស ធ្វើឲ្យសៅហ្មង ចាក់ឫសគល់ជាប់ស្អិតក្នុងសន្តានចិត្តមនុស្សសត្វទូទៅ ក៏បបួលគ្នា ឬបង្ខំឲ្យយល់ថាជា "**សច្ចធម៌**" ពោលគឺ "**អាទិទេព**" ពិតប្រាកដ ហើយចង់ជាទ្រឹស្ដីទុកថា "មានទេពតា" ដែលទស្សនវិទូទូទៅប្រើពាក្យ

ថា ភាពមានអត្ថិភាព (Entité) នៃទេពតា ។

ឯពាក្យដែលថា "ទេវៈ" ជា "សច្ចធម៌" ឬជា "ឯកសទអធិតីយម" មានសច្ចតែមួយ មិនមានពីរ (Unique) នេះទៀត ក៏ជាទ្រឹស្តីរបស់មនុស្សដែលជឿថា "មានទេពតា" ជាពាក្យវាយសេចក្តីឲ្យឃើញថា "មានពិត" ប្រសើរវិសេស ហើយគេទុកជា "សច្ចធម៌" ។ សច្ចធម៌នេះ បើជាមានពិតមែន ក៏ជាសម្មតសច្ច "សច្ចដោយសន្មត" ពុំមែនជាអរិយសច្ច "សច្ចប្រសើរពិត" នោះទេ ។

ព្រះសម្ពុទ្ធសមណគោតម ទ្រង់ពុំមែនជា "អាទិទេព" (God Dieu) ដូចជាមានទ្រឹស្តីនៃលទ្ធិសាសនា ឬពាហិរសាសនា បានបញ្ញត្តទុកមកនោះទេ ។ ព្រះអង្គជា "**មនុស្ស**" មនុស្សរកសភាវធម៌ពិត ឃើញតាមពិត ហើយទ្រង់បានជា "អ្នកយថាភូត" (Objectif) ទ្រង់ឃើញតាមពិតថា "**ការកើត = ជាតិ**" **នេះជាទុក្ខ ពោលគឺ "បើមានកើត = ជាតិ" នេះហើយ ធម៌ទាំងឡាយដែលជាបច្ច័យ គឺជរា ព្យាធិ មរណៈ ក៏តែងតែកើតមានឡើងជាធម្មតា** ។ ទ្រង់ឃើញសភាវធម៌ពិតថា "លោកនេះជាទុក្ខ" ដូច្នេះហើយ ទើបទ្រង់ស្វះស្វែងរកផ្លូវប្រតិបត្តិ "បដិបទា" ជាសន្តិវរបទ "សន្តិភាពស្ថាពរ" ហៅថា មជ្ឈិមាបដិបទា គឺផ្លូវកណ្តាល ផ្លូវត្រង់ ជាផ្លូវដែលអាចដោះលោក គឺទុក្ខនៃមនុស្សជាតិនេះ បានអស់ជើង មិនគួរមានសន្ទិះសង្ស័យឡើយ ។

## តើព្រះសម្ពុទ្ធនេះ គឺអង្គលោកណា?

**ប្រមាណជា៦២៣ឆ្នាំ មុនគ្រិស្តសករាជ** កាលនោះ មានសក្យរាជមួយព្រះអង្គ កើតឡើងក្នុងរដ្ឋនេប៉ាល់ដែនដីប្រទេសឥណ្ឌា មាននាមប្រាកដថា **គោតម សិទ្ធត្ថរាជកុមារ** ។ ព្រះជន្មាយុ១៦វស្សា ទ្រង់រៀបចំមង្គលាភិសេកជាមួយព្រះនាង**ពិម្ពាយសោធរា** ដែលជាខត្តិយាណីព្រះញាតិដ៏ជិត ។

អស់កំឡុង ១៣វស្សា ក្រោយប្រាប្តភិសេក ទ្រង់សោយក្តីសុខជាខត្តិយសុខុមាលជាតិ ។ ទ្រង់ប្រថាប់នៅក្នុងផ្ទៃព្រះបរមរាជវាំង បរិបូណ៌ដោយផាសុកគ្រប់ប្រការ មានប្រាសាទ៣ខ្នងសំរាប់រដូវកាលទាំង៣ មួយអន្លើដោយស្រីស្នំក្រុមការស្រីង្គារ ច្រៀងរាំ ប្រគំ ដេញ ដំ តូរ្យតន្ត្រីកំសាន្តព្រះរាជហឫទ័យឥតមានមោះហ្មងអ្វីឡើយ សូម្បីតែគ្រឿងទ្រង់ព្រះពស្ត្រភូសា ក៏សុទ្ធសឹងតែកោសេយ្យពស្ត្រដែនកាសី ទ្រង់ពុំដែលបាននឹកនាដល់ទុក្ខវេទនា ក្នុងជីវភាពប្រជាជនព្រះអង្គ ដែលរស់នៅក្រៅទ្វារព្រះបរមរាជវាំងឡើយ ។ លុះកាលវេលាមកដល់ ទើបសច្ចធម៌កើតមានឡើងនៅក្នុងព្រះទ័យព្រះអង្គ ។

ព្រះជន្មាយុ២៩វស្សា ព្រះសិទ្ធត្ថរាជកុមារ ស្តេចចេញប្រពាតក្រសាលកំសាន្តព្រះទ័យខាងក្រៅព្រះបរមរាជវាំង ទ្រង់បានជ្រាបសេចក្តីពិត ពោលគឺការទល់ទុក្ខវេទនាគ្រប់ប្រការទាំងអស់ ដែលលោកហៅថា "ទេវទូត = ទូតទេពតា" ពោលគឺសេចក្តីពិតនៃសភាវធម៌ទាំងឡាយ។ ទេសកាលនោះឯង ព្រះរាជបុត្រ គឺរាហុលកុមារប្រសូតថែមទៀត ។ ព្រះទ័យព្រះអង្គស្លុតរន្ធត់ដូចត្រូវរន្ទះបាញ់ទាំងប្រាំបីទិស។ ធម៌ទាំងនេះហើយ ជាទេវទូតមកគម្រាមព្រះអង្គ ទ្រង់សន្ធប់មួយសន្ទុះ ភ្ញាក់ព្រះអង្គឡើង ទ្រង់ដកដង្ហើមវែង ។ លាន់ព្រះឱសខ្លាំងៗថា "អាំ! រាហុចាប់អាត្មា

អញហើយតើ!” ។ ធម៌មានប៉ុណ្ណោះជាដើម ដែលទ្រង់ទុកជាអន្ទាក់ចងព្រះអង្គ ព្រោះថាធម៌ទាំងអស់នេះហើយ សុទ្ធតែជាធម៌នាំឲ្យមាន “ការកើតទៀត = បុនព្ភវោ” ។ ដោយទ្រង់យល់ច្បាស់ថា “នេះជាទុក្ខសកលលោក” ទើបទ្រង់មានព្រះទ័យចេញស្វះស្វែងរកឱសថសព្វគុណ (Panacea) ដើម្បីរក្សាជម្ងឺសកលមនុស្សលោក ។

កាលនោះ ព្រះអង្គបោះបង់រាជសម្បត្តិចោល ឥតស្រណោះ កាន់យកភេទជាតាបសសន្យាសិន ត្រាច់រង្គាត់ដើរស្វះស្វែងរកសច្ចធម៌ ។ ទ្រង់បានប្រាស្រ័យជាមួយនឹងតាបសច្រើននាក់ ដែលសុទ្ធតែជាអ្នកទទួលស្គាល់ថាជា “បរមគ្រូ” ប៉ុន្តែពុំមានតាបសណា សូម្បីតែម្នាក់ដែលមានភូមិការសិក្សាបរិបូណ៌ ល្មមនឹងថ្វាយវិស្សជ្ជនាដោះអាថ៌ប្រស្នា ធ្វើព្រះអង្គឲ្យពេញព្រះទ័យបានឡើយ ព្រោះតាបសទាំងនោះ គ្រាន់តែមាននាមថា “ទស្សនវិទូ” ប៉ុណ្ណោះ ហើយជាអ្នកមិនមានបញ្ញាចក្ខុ ដូចមនុស្សខ្វាក់ដឹកដៃមនុស្សខ្វាក់ លិចកប់បាត់នៅក្នុងអវិជ្ជា ដូចសុភាសិតបុរាណខ្មែរថា “ដំរីខ្វាក់ ទ្រមាក់ឆ្កួត” ហើយអណ្តែតទៅតាមខ្សែទឹក ពោលគឺវាលវែងវដ្តសង្សារ ។

ក្នុងការស្វែងរកសច្ចធម៌ ទ្រង់សាកល្បងរកគ្រប់វិធី ដែលគេយល់ថាជាផ្លូវនាំទៅកាន់ការរួចចាកទុក្ខ (មោក្សធម៌) ។ ទ្រង់ប្រព្រឹត្តព្រហ្មចរិយធម៌តាមបែបព្រាហ្មណ៍ គឺប្រព្រឹត្តយោគៈ “វិធីទូន្មានចិត្ត” ប្រព្រឹត្តយោគៈហើយ ទ្រង់ឃើញថាពុំមែនជាផ្លូវត្រង់ទៅកាន់ទីបំផុតទុក្ខ ទ្រង់ប្រព្រឹត្តតបធម៌ “វិធីទូន្មានកាយ”ទៀត ដែលយើងគ្រប់គ្នាដឹងថា ទុក្ករកិរិយា “ការធ្វើបានដោយកម្រក្រៃលែង” ។ ព្រះអង្គប្រព្រឹត្តតាមវត្តប្រតិបត្តិសាសនាព្រាហ្មណ៍ទាំងអស់ ដែលគេយល់ថាជាវិធីប្រសើរក្នុងកាលនោះ ទ្រង់ប្រព្រឹត្តលាងបាបមួយបែបហើយមួយបែបទៀត អាំងភ្លើងដុតកំដៅបាប មួយហើយមួយទៀត ទាល់តែព្រះវរកាយស្គាំងស្គមរីងស្ងួតនៅតែស្បែកដណ្តប់ឆ្អឹង មើលទៅឃើញតែគ្រោងឆ្អឹងចង្រ្កឹង ធ្វើម្ល៉េងហើយ នៅតែមិនបានសម្រេចតាមពុទ្ធបំណងទៀត ។ វិធីព្រហ្មចរិយធម៌បែបនេះហើយពន្យល់ព្រះអង្គថា នេះពុំមែនជាវិធីទេ នេះពុំមែនជាអភិសម័យរបស់ព្រះអង្គទេ ក៏ព្រះអង្គបោះបង់ចោលទាំងអស់ទៅ ហើយតាំងព្រះទ័យស្វែងរកដោយទំនើងព្រះអង្គវិញ ទ្រង់ចៀសវាងផ្លូវចុង២ប្រការ គឺការពំនឿយខ្លួនឥតអំពើ (អត្តកិលមថានុយោគ) និងការច្របូកច្របល់ដោយកាម (កាមសុខល្លិកានុយោគ) ដាច់ស្រឡះ ។ ការស្វែងរកសច្ចធម៌នៃព្រះអង្គនេះ ប្រកបដោយវិរិយភាពខ្លាំងក្លាបំផុត ហួសកម្លាំងមនុស្សធម្មតាដែលនឹងអាចធ្វើបាន ហើយត្រូវប្រើវេលាប្រាំមួយវស្សាទៀត ។ ទីបំផុត ទ្រង់ឃើញថា ផ្លូវដែលទ្រង់ប្រតិបត្តិតាមលទ្ធិព្រាហ្មណ៍នេះ ពន្យឺតវេលានាំមិនឲ្យលុះពោធិញាណ ហើយផ្លូវដែលទ្រង់រកឃើញតាមទំនើងព្រះអង្គនេះ ធ្វើឲ្យព្រះអង្គភ្ញាក់រឭកកើតបញ្ញាញាណបាន ។ ផ្លូវថ្មីដែលទ្រង់រកឃើញ ជាផ្លូវកណ្តាល ហៅថា មជ្ឈិមាបដិបទា ជាផ្លូវប្រើការបាន ត្រង់ទៅរកពោធិញាណ ហើយបានជាមាគ៌ាត្រង់មួយក្នុងពុទ្ធសាសនាសម្រាប់សកលលោក ។

ព្រឹកថ្ងៃជ័យមង្គលមួយ នាពេញបុណ្ណមីខែពិសាខ ទ្រង់ប្រថាប់ក្រោមពោធិមណ្ឌល ឥតមានអានុភាពទេពតាណាមួយមកជួយណែនាំព្រះអង្គទេ មានតែវិរិយនិងបញ្ញាញាណរបស់ព្រះអង្គប៉ុណ្ណោះ ទ្រង់កំចាត់បង់នូវកិលេសាសវៈ ព្រមទាំងមោហាន្ធការដាច់ខាត ហើយទ្រង់

លុះសម្មាសម្ពោធិញ្ញាណ “ត្រាស់ដឹងធម៌” បានសម្រេចភាពជា “ពុទ្ធ = អ្នកត្រាស់ដឹង” ក្នុងជន្មាយុ ៣៥ វស្សា នៅឧរុវេលប្រទេស (ពុទ្ធគយា) ដែនមគធៈ (វឌ្ឍពិហារ) ។ បានត្រាស់ដឹងធម៌ហើយ ទ្រង់ឧទ្ទិសព្រះវរកាយ ព្រះវរជន្មជីព មានតម្លៃឥតអ្វីប្រៀបផ្ទឹមបាន ដើម្បីសកលលោក ដោយពុទ្ធចរិយាជាគម្រូ និងដោយធម្មវិន័យជាដំបូន្មាន ពុំមានមនុស្ស ឬទេពតាឯណាមួយប្រសើរត្រឹមស្មើនឹងព្រះអង្គបានឡើយ ។ ព្រះអង្គទ្រង់បំពេញកិច្ចការរាល់ទិវារាត្រី ហៅថា ពុទ្ធកិច្ច "កិច្ចដែលព្រះពុទ្ធត្រូវធ្វើរាល់ទិវារាត្រី" មាន៥ពេលគឺ ៖

១- **ពេលព្រឹក** ទ្រង់បិណ្ឌបាត;

២- **ពេលរសៀល** ទ្រង់ប្រទានធម្មទេសនាប្រោសសត្វ;

៣- **ពេលពន់ព្រលប់** ទ្រង់ប្រទានឱវាទភិក្ខុសង្ឃ;

៤- **ពេលអធ្រាត្រ** ទ្រង់វិសជ្ជនាអាថ៌ប្រស្នា ដែលទេពតាមកក្រាបទូលសួរ;

៥- **បច្ចូសសម័យ** ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វ ដែលទ្រង់ត្រូវប្រោស ។

គិតទៅ ក្នុង២៤ម៉ោង ទ្រង់មិនផ្ទំលក់ដូចមនុស្សធម្មតាទេ **ទ្រង់ប្រព្រឹត្តយ៉ាងនេះជានិច្ច-កាល អស់រយៈវេលា៤៥វស្សា** រហូតដល់និព្វាន គ្រាន់តែសម្រាកព្រះកាយមួយស្របក់ លាតតម្រង់ព្រះបិដ្ឋិលើសង្ឃាដី ដែលព្រះអានន្ទត្រូវតែងតែក្រាលថ្វាយ ។ ក្នុងលោកនេះ តើមានមនុស្ស ឬទេពតាណា ធ្វើការដើម្បីសកលលោក មិនចេះឈប់យ៉ាងនេះ ក្នុងមួយជីវិត ដូចព្រះសម្ពុទ្ធដែរឬទេ ? ដោយទ្រង់ជាមនុស្សជាតិ ទ្រង់ធ្វើការខ្លាំងពេក ត្រូវតែគ្រាំគ្រាព្រះវរកាយ ត្រូវតែទៅតាមធម៌អនិច្ចំ “ពុំថេរនៅនិត្យ” ហើយ**បរិនិព្វានក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា** ។

សេចក្តីខ្លីនេះ បញ្ជាក់គ្រប់គ្រាន់ថា “ **ព្រះសម្ពុទ្ធជាមនុស្ស** ” ទ្រង់សោយព្រះជាតិជាមនុស្ស មានព្រះជីពជន្មជាមនុស្ស ដោយទ្រង់ជាមនុស្ស មានព្រះជីពជន្ម ទ្រង់ត្រូវតែអស់ព្រះជន្មដូចមនុស្សធម្មតា ។ ប្លែកតែ**ព្រះអង្គជាអច្ឆរិយមនុស្ស** = មនុស្សអស្ចារ្យ ដែលសកល-លោកពុំដែលមាន ។ នេះជាចំណុចធំបំផុត នៅក្នុងសក្ខីភាពចំពោះអង្គព្រះសម្ពុទ្ធ ពុំមានចន្លោះត្រង់ណាមួយ ដែលគួរឲ្យភ័ន្តច្រឡំឬទំនងឲ្យយល់ថា “ព្រះអង្គជាអមរទេពតា មិនចេះស្លាប់” នោះឡើយ ។ ដូច្នេះ ពុំគួរចាត់ទុក អង្គព្រះសម្ពុទ្ធជា “អាទិទេព” ទេ ឬនឹងទុកអង្គព្រះសម្ពុទ្ធជាអវតា (Incarnation) ព្រះវិស្ណុ ដូចអ្នកផងធ្លាប់តែជឿមកនោះក៏ទេដែរ ឬក៏នឹងទុកព្រះអង្គថាជាត្រាតា “អ្នកជួយលាងបាប” (Saviour) ដែលជួយលាងបាបអ្នកដទៃឲ្យរួចចាកភ័យដោយភក្តិ-មាគ៌ា (Salvation) របស់ព្រះអង្គ ក៏ពុំមែនទៀត ។ សេចក្តីពិត **ព្រះសម្ពុទ្ធជាសាស្តាចារ្យ** បណ្តុះកម្លាំងចិត្តសាវកព្រះអង្គឲ្យចេះទីពឹងខ្លួនឯង ដើម្បីរួចចាកខ្លួនឯង បញ្ជេះឲ្យយល់ពិតថា ក្តីបរិ-សុទ្ធិ និងមិនបរិសុទ្ធិ ស្រេចហើយតែបុគ្គលម្នាក់ៗទេ ។ ក្នុងធម្មបទ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទូន្មានថា “**អ្នកទាំងឡាយត្រូវធ្វើការឲ្យបានសម្រេចដោយខ្លួនឯង តថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវ** = **តុម្ហេហិ កិច្ចមាតប្បំ អក្ខាតារោ តថាគតា**” ។ ដូច្នេះ **ព្រះសម្ពុទ្ធជាអ្នកចង្អុលប្រាប់ផ្លូវ** បង្រៀនឲ្យចេះដើរខ្លួនឯង ទុកឲ្យយើងគ្រប់គ្នាធ្វើខ្លួនឯង ពោលគឺប្រតិបត្តិតាមមាគ៌ាដ៏ត្រង់នោះ ដើម្បីបានក្តីបរិសុទ្ធិខ្លួនឯង ។ និយាយខ្លី “ទីពឹងអ្នកដទៃ ដើម្បីរួចចាកភ័យខ្លួនឯង ជាអវិជ្ជមាន

(Negative) ពុំមែនជាវិធីទេ, ទីពឹងខ្លួនឯងដើម្បីរួចចាកភ័យខ្លួនឯង ទើបជាវិជ្ជមាន (Positive) ទើបជាវិធី” ពោលគឺទីពឹងអ្នកដទៃ បានសេចក្តីថា “យើងព្រមទទួលចាញ់វិរិយភាពបុគ្គលដទៃ” ពិតប្រាកដឥតជជែកបានឡើយ។ ពុទ្ធវចនៈដែលបណ្តុះកម្លាំងចិត្តសាវកទាំងឡាយឲ្យចេះទីពឹងខ្លួនឯង ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកនៅក្នុងមហាបរិនិព្វានសូត្រថា ៖ “**ភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរយកខ្លួនជាកោះពឹងខ្លួនឯង, ចូរយកខ្លួនជាទីពឹង ចូរកុំយកអ្នកដទៃមកធ្វើជាទីពឹងខ្លួនឡើយ** = **ភិក្ខវេ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា** ” ។

ដោយវិសេស ព្រះសម្ពុទ្ធ មិនមានពុទ្ធបំណងនឹងកាន់កាប់កិច្ចការបែបជា ឯកាធិបតេយ្យ (Monopoly) ឲ្យសម្រេចពុទ្ធភាពដាច់មុខតែមួយព្រះអង្គទេ សេចក្តីពិត ពុទ្ធភាពនេះ ពុំមែនជាបុព្វសិទ្ធិ (Prerogative) សម្រាប់បុគ្គលវិសេសណាមួយទេ ទ្រង់បានឡើងឋានៈខ្ពង់ខ្ពស់ប្រសើរយ៉ាងនេះ ដោយបារមីធម៌ (State of Perfection) ដែលបុគ្គលណាមួយប្រាថ្នាចង់បាន ក៏អាចសម្រេចដូចគ្នាដែរ ពុំមែនជាការបិទទ្វារនៃសាស្តាចារ្យណាមួយថា បើនឹងបាន លុះត្រាតែបានទទួលទេវឱង្ការ ហើយទើបសម្រេចបាននោះទេ ។ ពុទ្ធវចនៈដែលមានប្រាកដក្នុងព្រះត្រៃបិដកស្តីទុកថា ជនណាម្នាក់ ក៏អាចលុះភាពជាព្រះពុទ្ធបានដូចៗគ្នា ឲ្យតែអ្នកនោះ ប្រតិបត្តិត្រឹមត្រូវទៅតាមគន្លងបារមីធម៌ ដែលជាមាគ៌ាដើរត្រង់ទៅកាន់ ពោធិញ្ញាណ ។ ព្រះសម្ពុទ្ធ ពុំចេះដាក់ទោសបុគ្គលណាម្នាក់ ដោយពុទ្ធដីកាថា “**អ្នកត្រូវមានទោស**” ដូច្នេះទេ ផ្ទុយទៅវិញ ទ្រង់តែងតែព្រះមេត្តាប្រោសទេសនាទូន្មានដោយពុទ្ធដីកាថា ៖ “**ភិក្ខុទាំងឡាយ! ចិត្តជាធម្មជាតិបរិសុទ្ធផូរផង់ពីកំណើត តែចិត្តនេះ កាលណាបើមានឧបក្កិលេសថ្មីចូលទៅ ទើបសៅហ្មង** = **បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ ចិត្តំ អាគន្តុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ** ” ។

តាមពុទ្ធវចនៈនេះ ពិភពលោកយើងនេះ ពុំមែនជាអាក្រក់ទេ ប៉ុន្តែសត្វទាំងឡាយ តែងតែវង្វេងដោយអំណាចអវិជ្ជា ដែលជាធម៌សឹកសត្រូវធំបំផុតរបស់សត្វទាំងឡាយ ។ ទ្រង់តែងតែមានមេត្តាប្រោសប្រទានឱវាទ ដល់សាវកព្រះអង្គ កុំឲ្យមានចិត្តរួញរា ធ្វើសាវកព្រះអង្គ ឲ្យដកដង្ហើមស្រួល ឲ្យរីករាយ ឲ្យអាចហ៊ាន ឲ្យក្លាហាន ឲ្យទុកចិត្តខ្លួនឯង ហើយឲ្យប្រើវិរិយភាពខ្លួនឯងឲ្យមុះមុត ដើម្បីបានឃើញធម៌ដូចព្រះអង្គ ។

ពិសេសទៅទៀត ដោយព្រះអង្គមានភាពជាមនុស្ស ហើយប្រើវិរិយភាពខ្លាំងក្លាឲ្យបានសម្រេចភាពជា “**ពុទ្ធ**” ទ្រង់ប្រកាសប្រាប់លោកទាំងមូលឲ្យយល់ច្បាស់តាមពិតថា “**មនុស្សលោកមានភាពអាចបាន**” (Possibilities) និង “**អានុភាពអាចធ្វើឲ្យសម្រេចបាន**” (Creative Power) កប់នៅក្នុងខ្លួនមនុស្ស ។ ធម៌ជាអាថ៌កំបាំងទាំងនេះហើយ ទុកជាអាទិទេពមានអំណាចលើមនុស្ស លុះត្រាតែអាទិទេពនេះប្រទាន ទើបមនុស្សលោកអាចសម្រេចប្រយោជន៍ខ្លួនឯងបាន ។ ព្រះសម្ពុទ្ធ ទ្រង់ចាប់លើកយកធម៌អាថ៌កំបាំងគឺ “**ភាពអាចបាន**” និង “**អានុភាពអាចធ្វើអ្វីឲ្យសម្រេចបាន**“ ទាំងពីរប្រការនេះ ទុកជាធម៌មានតម្លៃប្រសើរបំផុតមកបង្ហាញ មកប្រទានដល់មនុស្សលោក ព្រមទាំងទេវលោក ឲ្យឃើញច្បាស់ ឲ្យយល់ប្រយោជន៍ពិត ។ សេចក្តីពិត មនុស្សលោក ជាកែវមណីជោតិខ្លួនឯងដ៏វិសេស សម្រាប់បក់បោយយកប្រយោជន៍គ្រប់យ៉ាងនៅនាលោកនេះនិងបរលោក ។ វាសនាខ្លួន ឋិតនៅកប់ក្នុងខ្លួនមនុស្ស ឋិតនៅក្នុងកណ្តាប់ដៃ

មនុស្ស ។ ទ្រង់ទេសនាពន្យល់ថា "មនុស្សអាចទទួលនិយ្យានិកធម៌ដោយវិរិយភាពខ្លួនឯង មិនបាច់ពឹងពាក់អាទិទេព ឬអ្នកអាជ្ញាកណ្តាលណាមួយទេ" ។ **អាត្ម័ន** = ព្រលឹងកណ្តាល (Egocentric) នៃពិភពលោកនេះ មិនគឺអ្វីដទៃទេ គឺឧត្តមគតិដ៏ប្រសើរដែលស្តីថា << **មិនមានខ្លួនឯង = អនត្តា** >> នេះឯង ។ មិនមានវណ្ណៈ ចាត់ថ្នាក់មនុស្សលោកឲ្យទាបខ្ពស់ពីកំណើតទេ មនុស្សជាតិមានភាពស្មើគ្នា មានកាលគួរត្រូវបានសម្រេចដូចគ្នា នៅក្នុងដំណើរនៃជីវិតមនុស្សគ្រប់គ្នា ។

ព្រះសម្ពុទ្ធជាអ្នកបើកទ្វារឲ្យមនុស្សលោកបានសម្រេចផល ចំរុងចំរើន ថ្វីត្បិតតែមានការកើត = ជាតិនេះ ជាកំពែងរាំង ។ ទ្រង់បើកសេរីភាពពេញបរិបូណ៌ប្រទានដល់សត្វលោក ក្នុងការគិត ការធ្វើ ការនិយាយ បំបើកភ្នែកសត្វលោក ឲ្យមើលឃើញអ្វីៗ ឃើញពិតតាមពិត ជាយថាភូតទស្សនញាណ (Objectism) ទ្រង់សម្តែងធម៌ប្រោសសត្វដែលមានការព្រាត់ប្រាស ឲ្យមានចិត្តរឹងប៉ឹង ឲ្យមានចិត្តក្សេមក្សាន្តដោយពុទ្ធភាសិតគួរឲ្យមានក្តីកក់ក្តៅ ។ ទ្រង់ជាគ្រូពេទ្យព្យាបាលរោគចិត្ត ដែលគេរក្សាបានដោយក្រ អ្នកមានជម្ងឺឲ្យចេះបន្សាត់បង់ ឲ្យដកដង្ហើមស្រួលធូរទ្រូង ។ ទ្រង់ជួយអ្នកក្រីក្រដោយព្រះតម្រាស់ឲ្យចេះអប្បមាទធម៌ "ធម៌មិនប្រមាទ" ។ ទ្រង់ទូន្មានអ្នកធ្វើអំពើអាក្រក់ ឲ្យចេះធ្វើអំពើល្អ ឲ្យចេះធ្វើខ្លួនឲ្យបរិសុទ្ធ ។ ទ្រង់ទេសនាប្រោសអ្នកច្រអូសឲ្យមានក្តីក្លាហាន, អ្នកបំបែកបំបាក់គ្នាឲ្យមានសាមគ្គី, អ្នកល្ងង់ខ្លៅឲ្យចេះដឹងអ្វីដែលមានអាថ៌កំបាំងឲ្យមានពន្លឺ, អ្នកទាបថោកឲ្យខ្ពង់ខ្ពស់, អ្នកមិនប្រសើរឲ្យបានប្រសើរ ។ អ្នកមាន និងអ្នកក្រ សប្បុរស អសប្បុរស ពេញចិត្តព្រះអង្គគ្រប់ៗគ្នា ។ ព្រះរាជាសង្កត់សង្កិនរាស្ត្រ, ព្រះរាជាទសពិធរាជធម៌, ក្សត្រខ្ពង់ខ្ពស់, ក្សត្រទាបថោក, វរជន, មហាសេដ្ឋីចិត្តសប្បុរស,មហាសេដ្ឋីកំណាញ់, អ្នកប្រាជ្ញជាន់ខ្ពស់, អ្នកប្រាជ្ញជាន់ទាប, អ្នកទុរគតតោកយ៉ាក, អ្នកបោសថ្កល់ដែលត្រូវគេបៀតបៀន, ពេជ្ឈឃាត, នគរសោភិនី ទាំងអស់គ្នានេះ សុទ្ធតែត្រូវបានទទួលស្គាល់ពុទ្ធវចនៈ ដែលជាធម៌នាំឲ្យកើតបញ្ញា និងនាំឲ្យកើតព្រហ្មវិហារធម៌ ។

ចរិយាដ៏ប្រសើររបស់ព្រះពុទ្ធ ជាប្រភពដ៏វិសេសសម្រាប់មនុស្សគ្រប់គ្នា បក់បោយយកមកធ្វើជាតម្រាប់ខ្លួន ធ្វើគំរូគតិប្រចាំជីវិតខ្លួនបាន ។ មេត្តាគុណ ករុណាគុណ បញ្ញាគុណ របស់ព្រះសម្ពុទ្ធ គួរជាទីជ្រះថ្លា គួរជាទីគោរពបូជា គួរជាទីពេចពិលរមិលមើលនៃពួកជនអ្នកមានសទ្ធាទាំងឡាយ ។ ពុទ្ធវចនៈ ជាប្រភពនាំឲ្យកើតសន្តិភាព ជាធម៌សន្តិវរបទ គួរបានទទួលស្វាគមន៍ពីមជ្ឈដ្ឋានទូទៅ ដោយក្តីរីករាយក្រៃលែង ហើយជាធម៌ឲ្យផលជានិច្ចនិរន្ត ដល់ជនទាំងឡាយដែលមានវាសនាបានស្តាប់ បានប្រតិបត្តិតាមធម៌ព្រះអង្គ។ ធម៌ដែលព្រះអង្គបានសម្តែងហើយដោយប្រពៃនេះ បានផ្សព្វផ្សាយទូទៅពេញសកលលោក ហើយដក់ជាប់នៅក្នុងសន្តានចិត្ត កើតបានជាធម្មចរិយា ឬជាអរិយធម៌នៃប្រជាជនក្នុងសកលលោក ។ ការជឿនលឿនខាងវប្បធម៌នៃប្រទេសកាន់ពុទ្ធសាសនា សុទ្ធតែបានមកដោយអាស្រ័យពុទ្ធវចនៈដ៏ប្រសើរនេះឯង ។ ពុទ្ធសាសនានេះ សូម្បីកើតមានឡើងក្នុងលោក អស់ប្រមាណជា ២៥១៣ ឆ្នាំហើយ តែបុគ្គលិកលក្ខណៈអង្គព្រះសម្ពុទ្ធ និងព្រះធម៌ព្រះអង្គ នៅតែមានឥទ្ធិពលដ៏ខ្លាំងក្លាទៅលើពួកជនដែលបានទទួលក្រេបផឹករសព្រះធម៌ថ្លៃវិសេសនេះដរាប ។

* * *

# ពុទ្ធសាសនា

## ជាលទ្ធិសាសនា = Religion (ពាហិរសាសនា?)

ពុទ្ធសាសនា នឹងហៅថាលទ្ធិសាសនា ឬពាហិរសាសនា (Religion) តាមអត្ថន័យនៃពាក្យដូចអ្នកផងធ្លាប់យល់មកនោះក៏ទេ ព្រោះពុទ្ធសាសនាមិនមែនជាប្រព័ន្ធ (Systeme) នៃជំនឿឥតហេតុផល (Croyance) និងការបូជា (Culte) នោះឡើយ ។

ពុទ្ធសាសនាមិនព្រមប្រដៅពុទ្ធសាសនិកជនឲ្យមានជំនឿឥតហេតុផលទាល់តែសោះ ។ ជំនឿឥតហេតុផលនេះ ពុំមាននៅក្នុងពុទ្ធសាសនាឡើយ ។ ពុទ្ធសាសនិកជន ប្រើជំនឿដែរ តែជាជំនឿមួយបែបគឺ ជំនឿហេតុផល ជំនឿជាទីទុកចិត្ត (Confidence) ហើយមានប្រាជ្ញាប្រកបផង ដែលនៅក្នុងភាសាបាលី លោកហៅថា **សទ្ធា** **"ជំនឿហេតុផលប្រកបដោយបញ្ញា"** ។

ជំនឿឥតហេតុផលគឺជំនឿជឿអាទិទេពថា "អាទិទេពទទួលបាបខ្លួន ឲ្យខ្លួនបរិសុទ្ធ ហើយនាំឲ្យទៅកើតឋានសួគ៌" ។ ជំនឿបែបនេះ ពុំមែនជា "សទ្ធា" ដូចក្នុងពុទ្ធសាសនាទេ ។ ជំនឿ "សទ្ធា" ដែលពុទ្ធសាសនាប្រដៅឲ្យប្រើ ចំពោះអង្គព្រះសម្ពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានលក្ខណៈជ្រះថ្លាចំពោះគុណធម៌ ហើយមានលក្ខណៈហ៊ានពុះពារដើរទៅតាម គឺមានទំនងដូចអ្នកឈឺជឿទុកចិត្តលោកគ្រូពេទ្យថាអាចជួយរក្សាជម្ងឺខ្លួនឲ្យជាសះស្បើយបាន ហើយហ៊ានកាន់តាមពាក្យទូន្មានលោកគ្រូពេទ្យ ឬដូចជាសិស្សជឿលោកគ្រូថាគ្រូបាអាចារ្យរបស់ខ្លួន ជាអ្នកបង្រៀនខ្លួនឲ្យចេះចំណេះវិជ្ជាបាន ហើយហ៊ានប្រតិបត្តិតាមឱវាទរបស់គ្រូ ដោយយល់ច្បាស់ថា គ្រូបង្រៀនខ្លួនឲ្យចេះរស់ខ្លួនឯង ឲ្យចេះដើរខ្លួនឯង ។

ពុទ្ធសាសនិកជន យកអង្គព្រះសម្ពុទ្ធជាសរណៈ "ទីពឹង" របស់ខ្លួន ដោយប្រើប្រាជ្ញាពិចារណា តាមហេតុផលសព្វគ្រប់ ឃើញពិតថា "ព្រះអង្គបានឃើញធម៌" ហើយទ្រង់ទេសនាទូន្មានខ្លួនឲ្យប្រតិបត្តិតាមបដិបទាដែលទ្រង់រកឃើញ ដើម្បីឲ្យបានលុះទីបំផុតទុក្ខ **"មោក្ខធម៌"** ឬ **"និព្វាន"** ដូចព្រះអង្គ ។ ពុទ្ធសាសនិកជន មិនព្រមយកព្រះពុទ្ធជាទីពឹងដោយក្ដីសង្ឃឹមថា "ព្រះពុទ្ធនឹងស្រង់ខ្លួន (Salvate) គឺទទួលបាបពីខ្លួន ឲ្យខ្លួនបរិសុទ្ធហើយនាំទៅកើតឋានសួគ៌" ដូចគេស្រង់មនុស្សលង់ទឹកដូច្នោះទេ ។ ពុទ្ធសាសនិកជនជឿជាក់ថា "ធម៌អង្គព្រះសម្ពុទ្ធពុំមែនជាក្ដីស្រង់"(Salvation)នោះទេ ព្រោះព្រះពុទ្ធពុំមែនជា"អ្នកស្រង់"(Saviour) ព្រះពុទ្ធពុំដែលធានារ៉ាប់រងថានឹងលាងបាបសត្វទេ ហើយព្រះពុទ្ធពុំមានអានុភាពនឹងលាងជម្រះបាបអ្នកដទៃបានទៀតផង ។

សេចក្ដីពិត មិនមានអ្នកណាដទៃ អាចធ្វើខ្លួនឲ្យបរិសុទ្ធ ក្រៅពីខ្លួនឯងបានឡើយ ។ ការពឹងគេឲ្យជួយបែបនេះ ពុំមែនជាវិធីទេក្នុងលោកនេះ ។ **ខ្លួនឯងជួយខ្លួនឯង ទើបជាវិធី** ។ ព្រះសម្ពុទ្ធជាសាស្ដាចារ្យ ជាអ្នកទូន្មានសត្វ គ្រាន់តែជាអ្នកបង្រៀន ប្រាប់ផ្លូវ សត្វទាំងឡាយត្រូវដើរខ្លួនឯង ទទួលខុសត្រូវដោយខ្លួនឯង ពុទ្ធសាសនិកជន ទោះយោបីយកព្រះពុទ្ធជាទីពឹង ក៏ពុំមែនបណ្ដោយខ្លួនឲ្យចេះតែជឿតាមឥតបើគិតនោះទេ ។ ពុទ្ធសាសនិកជន មិនព្រមបោះបង់សេរីភាពខ្លួន ក្នុងការគិតពិចារណា រកហេតុផល ហើយចេះតែជឿប្រតិបត្តិអង្គព្រះសម្ពុទ្ធ

នោះទេ ។ ពុទ្ធសាសនិកជន មានសិទ្ធិសេរីភាពច្បាំងក្នុងខ្លួនពេញបរិបូណ៌ ។ ពុទ្ធសាសនិកជន មានសិទ្ធិដើរខ្លួនឯងពេញទី ប្រឹងប្រែងបំពេញបារមីធម៌ឲ្យចាស់ក្លាទំដោយខ្លួនឯង ដើម្បីឲ្យខ្លួនឯងលុះភាព "**ពុទ្ធ**" ពេញទីដូចព្រះអង្គសម្ពុទ្ធដែរ ។ ព្រះសម្ពុទ្ធជាបរមសាស្តាចារ្យដ៏លើសក្នុងការប្រទានសេរីភាពដល់សត្វទាំងឡាយទ្រង់ទេសនាទូន្មានបង្រៀនសត្វទាំងឡាយឲ្យចេះដើរដោយខ្លួនឯង ពុំមានសាស្តាចារ្យណាប្រៀបផ្ទឹមឲ្យត្រឹមស្មើនឹងព្រះអង្គបានឡើយ ។ **ធម្មវិន័យព្រះអង្គមិនមែនជាអាចរិយមុដ្ឋិ** "កណ្តាប់នៃអាចារ្យ" (កណ្តាប់ដៃនៃអាទិទេព) មិនមែនជាទិដ្ឋិ (Dogma) ពុំមែនជាវាទ (Doctrine) មិនមែនជាអន្តរវាទ (Doctrine ésotérique) មិនមែនជាពាហិរ–វាទ (Doctrine exotérique) ទេ = **ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ** ។

ក្នុងពុទ្ធសាសនា អ្នកដែលទើបនឹងចូលជាពុទ្ធសាសនិកជន ត្រូវប្រើវិចារណញ្ញាណ ឬត្រូវមានការយល់ត្រឹមត្រូវ ហៅតាមពុទ្ធសាសនាថាសម្មាទិដ្ឋិ "យល់ឃើញត្រឹមត្រូវ) (Vue correcte) ។ ដើម្បីនឹងបានយល់ពិតតាមគន្លងធម៌ ព្រះសម្ពុទ្ធត្រាស់ទេសនា (កាលាមសូត្រ) ទុកថា

**១- អនុស្សវា** កុំប្រកាន់ជឿអ្វីដែលឮតៗគ្នា មិនមានហេតុផល
**២- បរម្បរា** កុំប្រកាន់ជឿអ្វី ដែលគេធ្វើតៗគ្នាមិនមានដើមចុង
**៣- ឥតិកិរ** កុំប្រកាន់ជឿអ្វី ដោយអាងថាបានឮគេនិយាយមកដូច្នេះ
**៤- បិដកសម្បទា** កុំប្រកាន់ជឿអ្វី មើលទៅឃើញសមតាមគម្ពីរខ្លួន
**៥- តក្កហេតុ** កុំប្រកាន់ជឿអ្វី ដោយអាងហេតុស្មានយក (អនុមាន)
**៦- នយហេតុ** កុំប្រកាន់ជឿអ្វី ដោយអាងការត្រេះត្រិះ ឬកាត់តម្រូវ
**៧- អាការបរិវិតក្ក** កុំប្រកាន់ជឿអ្វី ដោយអាងការត្រិះរិះមើលតាមអាការ
**៨- ទិដ្ឋិនិជ្ឈានក្ខន្តិ** កុំប្រកាន់ជឿអ្វី ដោយអាងថាខ្លួនពេញចិត្ត
**៩- ភព្វរូបតា** កុំប្រកាន់ជឿអ្វី ថាអ្នកនេះជាអ្នកប្រាជ្ញ គួរជឿតាម
**១០- សមណោ នោ គរុ** កុំប្រកាន់ជឿថា "សមណៈនេះជាគ្រូយើង" ។

ព្រះសម្ពុទ្ធ ទ្រង់ប្រដៅទៀតថា អ្វីដែលជាកុសល អ្វីដែលប្រសើរ ដែលអ្នកបានឃើញពិតខ្លួនឯង ចូរប្រព្រឹត្តតាមចុះ, អ្វីដែលជាអកុសល អ្វីដែលមិនប្រសើរ ដែលអ្នកបានឃើញពិតខ្លួនឯង ចូរកុំប្រព្រឹត្តឡើយ ។ ក្នុងលទ្ធិសាសនាដទៃ (Religion) មានពាក្យប្រៀនប្រដៅប្រាកដដូច្នេះបានឬទេ? ពាក្យប្រៀនប្រដៅនេះ ព្រះសម្ពុទ្ធទ្រង់ទេសនាទុកយូរយារណាស់ហើយ ហើយថិតនៅតាមសំណៅដើមដដែល ឃើញហាក់នៅថ្មីៗ ។ ចូរពិចារណាមើលចុះ! ពុទ្ធវចនៈនេះ បញ្ជាក់ច្បាស់ថា "**ពុទ្ធសាសនាមិនព្រមប្រើជំនឿឥតហេតុផល**" នេះទេ ។ បុគ្គលម្នាក់ៗ មានសិទ្ធិប្រើសេរីភាពរបស់ខ្លួនក្នុងការគិត ការនិយាយ ការធ្វើ ។ គួរកត់ចំណាំទុកចុះថា "**ពុទ្ធសាសនាជាសាសនាប្រគល់សេរីភាព**" ។ ព្រះពុទ្ធជាអ្នកប្រទានសេរីភាព ពុំមែនជាអាចរិយមុដ្ឋិ "កណ្តាប់ដៃនៃអាចារ្យ" ទេ ។

សេចក្តីខាងលើនេះ មានប្រស្នាចោទសួរថា "ចុះហេតុម្តេច បានជាពុទ្ធសាសនិកជនគោ–រពព្រះពុទ្ធបដិមា? "

ពុទ្ធសាសនិកជនគោរពនមស្សការព្រះពុទ្ធបដិមា ពុំមែនសុំក្តីអនុគ្រោះ(faveur)ពីអាទិទេព

ទេ គឺគោរពអ្វីដែលជាតំណាងព្រះសម្ពុទ្ធ ។ ក្នុងពុទ្ធសាសនា ពុំមានសូត្រស្តុតិ (Priére) បន់ស្រន់អាទិទេពទេ ។ ការបូជាគ្រឿងសក្ការៈ ដូចជាទៀន ធូប ចំពោះព្រះពុទ្ធបដិមា ជាការបូជាគុណ មេត្តា ករុណា បញ្ញារបស់បុគ្គលប្រសើរដែលបានធ្វើប្រយោជន៍ដើម្បីសកលលោក ធ្វើហាក់ដូចកាលទ្រង់គង់ធរមាននៅឡើយ ហើយយកអង្គព្រះសម្ពុទ្ធជាគម្រូ ជាគតិប្រចាំចិត្ត ប្រតិបត្តិតាមធម្មវិន័យព្រះអង្គ តាមចរិយាព្រះអង្គ ដើម្បីធ្វើខ្លួនឲ្យបានឃើញធម៌ដូចព្រះអង្គ ។

ដោយគារវកិច្ច ដោយកតញ្ញូតាធម៌ ពុទ្ធសាសនិកជន ត្រូវតែបំពេញកិច្ចទាំងនោះដើម្បីបូជាគុណ ។ ព្រះសម្ពុទ្ធមិនមានពុទ្ធបំណងធំចំពោះគ្រឿងសក្ការៈបូជានេះទេ ពុទ្ធបំណងដែលសំខាន់បំផុតនោះ គឺការប្រតិបត្តិតាមធម៌វិន័យ ឲ្យបានត្រឹមត្រូវតាមគន្លងធម៌ ដែលជាវិធីនាំសព្វសត្វឲ្យរួចចាកទុក្ខគ្រប់ប្រការ ។ ក្នុងមហាបរិនិព្វានសូត្រ ទ្រង់ត្រាស់ថា “ភិក្ខុទាំងឡាយ! បូជាមាន២ប្រការ គឺ អាមិសបូជា និងបដិបត្តិបូជា ។”

១- **អាមិសបូជា** បូជាគ្រឿងសក្ការៈ ទៀន ធូប ភ្ញីផ្កា ការបូជាទាំងនេះ មិនមែនជាការសំខាន់អ្វីពេកទេ តែពុទ្ធសាសនិកជន ពេញចិត្តធ្វើ ។

២- **បដិបត្តិបូជា** បូជាគឺការប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យព្រះអង្គ ។

បូជាពីរប្រការនេះ បដិបត្តិបូជា គឺការប្រតិបត្តិត្រឹមត្រូវតាមធម្មវិន័យ ជាការបូជាប្រសើរលើស ។ ទ្រង់ត្រាស់ថា អ្នកណាបូជាព្រះអង្គដោយបដិបត្តិបូជា គឺប្រតិបត្តិត្រឹមត្រូវតាមធម៌ អ្នកនោះឈ្មោះថា គោរព-រាប់អាន-បូជាតថាគត-ដោយការបូជាដោយប្រសើរលើស ។ ក្នុងទីដទៃទៀត ទ្រង់ត្រាស់ចំពោះវក្កលិភិក្ខុ ថាៈ **“អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត”** ។

សេចក្តីពិត ពុទ្ធសាសនាពុំមានវិធីស្តុតិទេ វិធីបន់ស្រន់អង្វរករ ក៏ពុំមានដែរ ព្រោះវិធីស្តុតិបន់ស្រន់ អង្វរករ ទាំងអស់នេះ ពុំមែនជានិយ្យានិកធម៌ “ធម៌ស្រោចស្រង់” ទេ ។ ព្រះសម្ពុទ្ធប្រោសសត្វដែលសូត្រស្តុតិបន់ស្រន់ឬអង្វរករព្រះអង្គពុំកើតទេ ។ ធម៌ព្រះអង្គ ជាធម៌ស្រោចស្រង់ខ្លួនឯង (និយ្យានិកធម៌) ប្រែថា “សេចក្តីបរិសុទ្ធិត្រូវធ្វើដោយខ្លួនឯង” ។ ព្រះសម្ពុទ្ធឃើញថា “សូត្រស្តុតិថ្វាយព្រះអង្គ ជាការឥតប្រយោជន៍” ហើយទ្រង់ពុំយល់ឃើញត្រឹមតែប៉ុណ្ណឹងទេ ទ្រង់ឃើញទៀតថា “ការសូត្រស្តុតិ សុំក្តីអនុគ្រោះនេះ ជាការបន្ទាបបន្ថោកខ្លួន ហើយធ្វើខ្លួនឲ្យមានគំនិតថោកទៀតផង” ។ ពុទ្ធសាសនិកជន ពុំគួរសូត្រស្តុតិ ដើម្បីស្រោចស្រង់ខ្លួនទេ ត្រូវទុកចិត្តខ្លួនឯង ធ្វើខ្លួនឯង ដើម្បីសេរីភាពខ្លួនឯង ។

ពុទ្ធសាសនា ពុំមានអាទិទេព ពុំមានជំនឿចំពោះពលានុភាពពិភពលោក ដែលស្មីថាមាន “ការចេះដឹងសព្វ ឬសព្វជ្ញ” (Omniscience) មាននៅសព្វកន្លែង ឬសារពើឋាន (Omnipresence) ពុំមានទិដ្ឋិ (Dogma) ដែលត្រូវប្រកាន់ជឿ, ពុំមានលទ្ធិ (Creed) ដែលត្រូវទទួលជំនឿ (Foi) ពុំមានព្រាហ្មណ៍ធ្វើជាអាជ្ញាកណ្តាល រវាងមនុស្សនិងអាទិទេព, ពុំមានពិធី រីត៍ពិសេស (Rite), ពុំមានពីធីសំស្ការ(១) ធ្វើឲ្យកើតបានជាពុទ្ធសាសនិកជន, ពុំមានមុន្ត្រៈ (បទសូត្រស្តុតិ) ឬយជ្ញពិធី,

-------------------

(១) ពិធីប្រសិទ្ធីឲ្យបានជាព្រាហ្មណ៍ ។

ពុំមានការប្រព្រឹត្តព្រហ្មចរិយ គឺតបធម៌ ដើម្បីស្រោចស្រង់ខ្លួនទេ ។

ដូច្នេះ ពុទ្ធសាសនា អ្នកផងពុំគប្បីហៅថា Religion (លទ្ធិសាសនា) ពេញទ្រពងមាន់សោះ ព្រោះពុទ្ធសាសនាពុំមែនជាប្រព័ន្ធ (Système) នៃជំនឿឥតហេតុផល (Foi) និងការបូជា (Culte) ទេ ឬនឹងថាជា "អំពើដែលដឹកនាំមនុស្សឲ្យទទួលស្គាល់អាទិទេព ឬអាទិទេពត្រូវមានអានុភាពលើវាសនាខ្លួនជាមនុស្ស ហើយមនុស្សត្រូវតែគោរពបូជា សូត្រស្តុតិ ជាកិច្ចតបស្នងសងគុណវិញ" ដូច្នេះក៏ទេដែរ ។

បើនឹងហៅពុទ្ធសាសនាថា Religion *"លទ្ធិសាសនា"* ដោយមានអត្ថន័យថា "ជាពុទ្ធវចនៈដែលស្តីពីជីវិត ចូលទៅដល់ក្នុងជីវិត តាមយថាភូតទស្សនញាណ ពុំមែនគិតសើៗ តែសំបកក្រៅនោះទេ ជាពុទ្ធវចនៈស្តីពីដំបូន្មាន ផ្តល់ឲ្យមនុស្សចេះប្រតិបត្តិ ចេះដើរខ្លួនឯង ដោយតាមគន្លងដំបូន្មានល្អិត សុខុម ត្រឹមត្រូវ វិសេស, ជាពុទ្ធវចនៈស្តីពីដំបូន្មាន បង្រៀនមនុស្សឲ្យមានក្តីមានះតស៊ូយកឈ្នះខ្លួនឯង ចេះរស់ក្នុងជីវិតដោយប្រយ័ត្ន ចេះតស៊ូចំពោះសេចក្តីស្លាប់ មិនរួញរា មិនថ្ងូរ មិនញញើត ដោយខន្តីធម៌, ជាពុទ្ធវចនៈទុកជាអាគមសក្តិសិទ្ធ ស្តោះបណ្តុះបណ្តាលក្តីប្រសើរ ក្តីល្អ ក្តីរីករាយ ឲ្យកើតដល់ខ្លួនឯង និងដល់ជនដទៃទូទៅ " ។ បើពុទ្ធ-សាសនា ជាលទ្ធិសាសនា មានអត្ថន័យដូចពោលមកខាងលើនេះមែន នុ៎ះលទ្ធិសាសនានេះឯង ប្រាកដជាប្រសើរលើស លើលទ្ធិសាសនាទាំងឡាយ (A religion of religions) ។

★

★ ★

# ព្រះធម៌ដែលព្រះសម្ពុទ្ធសម្តែងប្រោសសត្វ ជាទស្សនវិជ្ជាឬអ្វី?

**ព្រះធម៌** ឬហៅថា "**ធម្ម**" ដែលព្រះសម្ពុទ្ធសម្តែងហើយនេះឬ ដែលអ្នកបស្ចិមហៅថា "ទស្សនវិជ្ជា" (Philosophie) ? ក្នុងអតីតកាល មានព្រះសម្ពុទ្ធច្រើនព្រះអង្គ ដែលនិព្វានកន្លងរំលងទៅយូរអង្វែងណាស់ហើយ តែព្រះធម៌ថ្លៃវិសេសដែលទ្រង់បានសម្តែងទុកហើយដើម្បីប្រោសសត្វលោកនេះ ឋិតថេរនៅបរិសុទ្ធតាមរូបដើមដដែល ហេតុនេះហើយបានជាព្រះធម៌នេះហៅថា **បកតិធម៌** "ធម៌ប្រក្រតី" ។

ព្រះធម៌នេះ កាលព្រះអង្គគង់ធរមាននៅឡើយ មិនមានចារឹកជាអក្សរទេ ។ ក្រោយពុទ្ធបរិនិព្វាន ព្រះអរិយសាវកទាំងឡាយច្រើនអង្គ បានធ្វើសង្គាយនា(១) (ផ្ទៀងផ្ទាត់) ពុទ្ធវចនៈទាំង

---

(១) មើលសៀវភៅ "ព្រះត្រៃបិដកជាភាសាខ្មែរ" នៅពុទ្ធសាសនបណ្ឌិត្យ

អស់ ចាំរត់មាត់ស្ទាត់ (មុខបាឋ) បានរក្សាព្រះធម៌ជាពុទ្ធវចនៈតៗគ្នាពីជំនាន់មួយទៅជំនាន់មួយទៀត ទុករហូតដល់បច្ចុប្បន្នកាលនេះ ។ ពុទ្ធសាសនាកន្លងទៅប្រមាណជា៥០០ឆ្នាំ ព្រះសង្ឃសាវកចារឹកពុទ្ធវចនៈជាលាយលក្ខណ៍អក្សរនៅកោះលង្កា ។ ព្រះសម្ពុទ្ធសម្តែងទុកថា ធម៌ព្រះអង្គនេះហៅថា **ធម្មវិន័យ** គឺធម៌១ វិន័យ១ តមកលោកចែកធម៌ជាពីរប្រការ គឺធម៌ដែលមានអាថ៌រាក់ ហៅថា "**ព្រះសូត្រ**" ធម៌ដែលមានអាថ៌ជ្រាលជ្រៅ ហៅថា "**ព្រះអភិធម្ម**" កើតបានទៅជា៣ផ្នែកគឺ **ព្រះវិន័យបិដក** (មាន១៣សៀវភៅ) **សុត្តន្តបិដក** (មាន៦៣សៀវភៅ) **អភិធម្មបិដក** (មាន៣៤សៀវភៅ) រួមហៅថា **តិបិដក** ឬ **ត្រៃបិដក** ឬក៏ **ឃ្លាំងបី** (Trible corbeille) ។

**១- វិន័យបិដក** "**ឃ្លាំងវិន័យ**" ជាច្បាប់ក្រិត្យក្រម ដែលព្រះសម្ពុទ្ធសម្តែងបញ្ញត្តអនុញ្ញាត ទុកសម្រាប់ជាផ្លូវប្រតិបត្តិពុទ្ធបរិស័ទ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ វិន័យនេះចែកជាពីរប្រការទៅទៀតគឺ ៖

ក/ **អាគារវិន័យ** "វិន័យអ្នកមានផ្ទះ" វិន័យសម្រាប់គ្រហស្ថ ឧបាសក ឧបាសិកាប្រតិបត្តិ ។

ខ/ **អនាគារវិន័យ** "វិន័យអ្នកមិនមានផ្ទះ" បានដល់អ្នកបួស គឺភិក្ខុ ភិក្ខុនី ប្រតិបត្តិ ។

**២- សុត្តន្តបិដក** ឬ **ព្រះសូត្រ** បានដល់ធម៌ដែលព្រះសម្ពុទ្ធសម្តែងក្នុងសម័យផ្សេងៗ កាលដែលទ្រង់គង់ធរមាននៅឡើយ។ ក្នុងព្រះសូត្រនេះ ព្រះសារីបុត្រ ព្រះមោគ្គល្លានព្រះអានន្ទ ឬព្រះសាវកដទៃទៀតសម្តែង ក៏មានដែរ ។

**៣-អភិធម្មបិដក** ឬ **ព្រះអភិធម្ម** ស្តីពីធម៌ល្អិតសុខុមជ្រាលជ្រៅ បានដល់ទស្សនវិជ្ជា មានអាថ៌គម្ពីរភាពរបស់ព្រះសម្ពុទ្ធ ជាអត្ថបទផ្ទុយពីសុត្តន្តបិដកដែលមានសេចក្តីរាក់ៗ គឺសុត្តន្តបិដកជាវោហារទេសនា (Conventional teaching), ឯអភិធម្មបិដក ជាបរមត្ថទេសនា (Ultimate teaching) ។ ក្នុងគម្ពីរអភិធម្ម ព្រះសម្ពុទ្ធសម្តែងពីធម៌ល្អិតសុខុមគឺស្តីពីចិត្ត (Consciousness) ចេតសិក (Mental concomitants), រូប (Matter) និងនិព្វាន ។ នៅក្នុងអភិធម្មនេះហើយដែលព្រះសម្ពុទ្ធសម្តែងទុកថា សព្វសត្វទាំងឡាយគ្រាន់តែជាបុគ្គល "បុគ្គលបញ្ញត្តិ = គ្រាន់តែជាបញ្ញត្តិថាជាបុគ្គល" នឹងជាសត្វ ក៏ពុំមែន នឹងថាមានជីវិតក៏ពុំមែន ជាធម៌សូន្យ = **និស្សត្តោ និជ្ជីវោ សុញ្ញោ** ដោយការវែកញែកយ៉ាងល្អិតបំផុត ត្រាតែញែកទៅទៀតពុំបាន ព្រមទាំងចែកធម៌ទាំងនេះដោយបរិយាយជាអនេកប្រការយ៉ាងម៉ត់ចត់បំផុតទៀត ។

មួយទៀត **អភិធម្មនេះ ស្តីពីសច្ចធម៌ (Truth) និងភូតធម៌ (Fact)** មិនស្តីពីទ្រឹស្តី ឬទស្សនវិជ្ជា ដែលគេទុកដូចជាសច្ចធម៌មានក្តីជ្រាលជ្រៅ បានតែពេលនេះ ហើយដល់ថ្ងៃស្អែកគេបដិសេធចោលទៅវិញ ដោយឃើញមិនពិតដូច្នេះទេ ។ ព្រះសម្ពុទ្ធសម្តែងធម៌ប្រដៅសត្វទាំងឡាយ ជាធម៌ប្រក្រតី ពុំមែនជាធម៌នាំឲ្យគេភ័យខ្លាចនោះទេ ពុំមែនជាទ្រឹស្តីទស្សនវិជ្ជាបែបថ្មីក្រៅចាកធម៌នោះទេ ឬនឹងថាជាធម៌ដែលទ្រង់ហ៊ានបង្កើតជាបែបវិទ្យាសាស្ត្រសម្ភារនិយមថ្មី

នោះក៏ទេដែរ ។ ទ្រង់តែងសម្ដែងធម៌ប្រោសប្រៀនប្រដៅដោយពន្យល់ថា "**ធម៌នេះជាមាគ៌ាគួរប្រតិបត្តិ ធម៌នេះពុំគួរប្រតិបត្តិ**" ដែលសុទ្ធតែជាធម៌នាំសត្វឲ្យរួចចាកទុក្ខ ហើយទីបំផុតទ្រង់ចង្អុលប្រាប់ផ្លូវទៅកាន់មោក្ខធម៌ ជាផ្លូវតែមួយគត់ ( = **ឯកាយនោមគ្គោ**) ។ បើពិនិត្យមើលឲ្យសព្វគ្រប់ទៅ ធម៌ព្រះអង្គជាធម៌ ដូចជាបើកបង្ហាញផ្លូវអ្នកវិទ្យាសាស្ត្រ ទស្សនវិទូច្រើននាក់ឲ្យដើរតាមក្រសែព្រះតំរិះព្រះអង្គទៀតផង ។ សេចក្ដីនេះ លោក **សូប៉េនហៅ** (Schopenhauer) សរសេរថា " **សេចក្ដីទុក្ខជាសច្ចធម៌ ហើយគំនិតនេះ បានជាមាគ៌ាដើរនៃទស្សនវិទូបស្ចិមសព្វថ្ងៃនេះទៀតផង**" ។ លោក **ស្ពីនោស៊ា**(Spinoza) ក៏ពោលបដិសេធចោលទ្រឹស្ដីទាំងឡាយដទៃដែរ ដោយលោកពោលថា " **សភាវធម៌ដែលលោកថា << ថេរនៅនិត្យនេះ >> មិនមានប្រាកដការនិយមទេ** " លោកបញ្ជាក់ទៀតថា "**សភាវធម៌ទាំងអស់ដែលថា <<ថេរនៅនិត្យ>> សុទ្ធតែមានការប្រែប្រួលធម្មតា** " ។ ចំពោះមតិលោកនេះ លោកយល់ថា <<**ទុក្ខនេះ មនុស្សអាចយកឈ្នះបាន ដោយរកឃើញធម៌គឺវិជ្ជាដែលពុំមែនជាធម៌កើតមានមួយស្របក់ និងពុំមែនជាធម៌កើតមានមួយភ្លែត តែជាធម៌ឥតកែប្រែបាន ថេរនៅនិត្យ ថេរចិរកាល**>> ។ លោក **បើរក្លេយ** (Berkley) យល់ច្បាស់ថា "**អ្វីដែលជាបរមាណូញែកពុំបាននេះ គេប្រឌិតទុកតែខាងបរមត្ថវិជ្ជាទេ គ្រាន់តែជាល្បែងលេង** " ។ ហើយលោក **ហូម** (Hume) ក្រោយដែលលោកវែកញែកពីរឿងចិត្ត (Mind) មកកាលយូរ លោកពោលសរុបសេចក្ដីថា "**វិញ្ញាណគឺធម្មជាតិដែលហូរទៅនៃចិត្ត**" ។ ឯលោក **បែរសុង** (Bergson) ពន្យល់ប្រាប់ថា "**នេះគឺច្បាប់នៃការប្រែប្រួល**" ។ ចំណែកលោកសាស្ត្រាចារ្យ **ជែម** (James) នាំយើងឲ្យយល់ថា "**នេះគឺក្រសែចិត្ត**" ។

ធម៌ដែលអ្នកប្រាជ្ញទាំងឡាយជួញចិត្តត្រិះរិះគិត ទាំងអស់នេះ ព្រះសម្ពុទ្ធ បានត្រាស់ទេសនាប្រោសសត្វប្រមាណជា ២៥៥៧ រួចមកហើយ នៅតាមដងមហានទីគង្គានៃប្រទេសឥណ្ឌា គឺទ្រង់ទេសនាប្រាប់ថា **នេះគឺអនិច្ចតាធម៌** "**ធម៌ប្រែប្រួលកើតមានតែមួយស្របក់ (ឧប្បាទធម៌ = Transieney),** **នេះគឺទុក្ខ** "**ធម៌ដែលទ្រាំទ្របានដោយលំបាកណាស់ (sarrow)** " **នេះគឺអនត្តា** "**ធម៌ដែលមិនមែនជារបស់ខ្លួនឯង (No soul)** " ហៅថាព្រះត្រៃលក្ខណ៍ ឬសាមញ្ញលក្ខណៈ "លក្ខណៈធម៌ដែលជាច្បាប់ទៀងទាត់បីប្រការ" ឬ "លក្ខណៈធម្មតាទាំងឡាយ ដែលតែងកើតមានឡើងជាប្រក្រតី" ។ មួយទៀត អ្នកសិក្សាពុទ្ធវចនៈ គប្បីយល់ថា ព្រះសម្ពុទ្ធទ្រង់ទេសនាធម៌ប្រោសសត្វទាំងឡាយ ទ្រង់ពុំបានទេសនាធម៌ទាំងអស់ដែលទ្រង់ត្រាស់ដឹងនោះទេ ទ្រង់ទេសនាចំពោះតែធម៌ណាដែលដឹកនាំសត្វទៅកាន់ទីបំផុតទុក្ខ គឺអមតមហានិព្វាន ។ សេចក្ដីនេះ មានប្រាកដនៅក្នុងគម្ពីរសំយុត្តនិកាយ មហាវារវគ្គថា ៖

ថ្ងៃមួយ ព្រះសម្ពុទ្ធ ទ្រង់ប្រថាប់នៅក្នុងសីសបាវ័ន ជិតក្រុងកោសម្ពិ ពេលនោះទ្រង់ឈោងព្រះហស្តទៅចាប់ស្លឹកឈើមួយក្ដាប់មក ហើយទ្រង់លើកឡើង រួចត្រាស់ទៅកាន់ភិក្ខុ

សង្ឃថា៖

“ **អ្នកទាំងឡាយ! ស្លឹកឈើដែលនៅក្នុងក្ដាប់ដៃតថាគតនេះ និងស្លឹកឈើដែលនៅលើដើមឈើទាំងឡាយ ណាច្រើនជាងណា?** ”

ភិក្ខុសង្ឃក្រាបទូលស្នងព្រះពុទ្ធដីកាវិញថា ៖

“**សូមទ្រង់ព្រះមេត្តាប្រោស! ស្លឹកឈើនៅក្នុងក្ដាប់ព្រះហស្តតិចណាស់ ស្លឹកដែលនៅលើដើមឈើ ច្រើនក្រៃលែងច្រើន ច្រើនលើសនឹងគណនាត្រាប់បាន**” ។

ពេលនោះព្រះសម្ពុទ្ធទ្រង់ត្រាស់តទៅទៀតថា ៖

“**អើភិក្ខុទាំងឡាយ! ធម៌ដែលតថាគតត្រាស់ដឹងនោះច្រើនណាស់ ដូចស្លឹកឈើដែលនៅលើដើមឈើ ហើយធម៌ដែលតថាគតយកមកសម្ដែងប្រាប់អស់អ្នកទាំងឡាយនេះ តិចណាស់ ដូចជាស្លឹកឈើដែលនៅក្នុងក្ដាប់ដៃតថាគតនេះឯង ។ តែធម៌ដែលតថាគតមិនបានយកមកសម្ដែងប្រាប់អ្នកទាំងឡាយ ជាធម៌មិនមានប្រយោជន៍នឹងដឹកនាំអ្នកទាំងឡាយទៅកាន់ទីបំផុតទុក្ខទេ** ” ។

ធម៌ដែលព្រះសម្ពុទ្ធយកមកសម្ដែងប្រោសសត្វទាំងឡាយ សុទ្ធតែជាធម៌មានប្រយោជន៍នឹងនាំសត្វទាំងឡាយទៅកាន់ទីបំផុតទុក្ខគឺនិព្វាន ជាធម៌គួរល្មមដល់មនុស្សទាំងឡាយចាប់យកសេចក្ដីហើយយល់បាន ជាធម៌ប្រកបដោយហេតុផលបរិបូណ៌ ហើយច្បាស់លាស់ប្រាកដការនិយម មានលក្ខណៈជាវិទ្យាសាស្ត្រ បើបុគ្គលណាមួយបានសិក្សាធម៌ទាំងនេះហើយ នឹងបានយល់ច្បាស់ ឃើញច្បាស់ មើលអ្វី មើលឃើញពិតដោយពិត ដោយយថាភូតទស្សនញាណ ជាធម៌ដែលអ្នកប្រាជ្ញបច្ចុប្បន្នកាលនេះទទួលស្គាល់ថាត្រឹមត្រូវ ហើយគេកោតស្ងើចក្រៃលែង ។

**សេចក្ដីពិត ពុទ្ធសាសនា និងវិទ្យាសាស្ត្រ មានលក្ខណៈស្របគ្នា ដើរទៅតាមផ្លូវជាមួយគ្នា** ។ រឿងនេះមិនមានទោសជាចន្លោះគួរឲ្យមានមោះមន្ទិលឡើយ គ្រាន់តែមួយជាផ្លូវធម៌ស្ដីពីសីលធម៌និង**បរមត្ថសច្ច** (Moral and spiritual truth) មួយទៀតជាផ្លូវលោក ស្ដីពី**សម្មតិសច្ច** (Material truth) ពោលគឺពុទ្ធសាសនាយកខ្លួនប្រើជាឧបករណ៍សម្រាប់ធ្វើនិទស្សន៍ រកសច្ចធម៌ ហើយប្រើតែ ខាងផ្នែក**សីលធម៌**ឬផ្លូវចិត្ត ជា**និរាមិសនិយម** ឬនឹងហៅថា **អរូបនិយម**ក៏បាន ឯវិទ្យាសាស្ត្រ យកវត្ថុដទៃក្រៅពីខ្លួនជាឧបករណ៍មកធ្វើជាជំនួយជួយធ្វើនិទស្សន៍រកសច្ចធម៌ ហើយយកទៅ ប្រើខាងផ្នែក**សម្ភារនិយម** ឬ**អាមិសនិយម** ឬក៏នឹងហៅថា**រូបនិយម**ក៏បាន ។ **បើនិយាយជា សេចក្ដីមួយបែបទៀត ពុទ្ធសាសនារកសេចក្ដីសុខនៅនាលោកនេះផង រកបរមសុខនៅឯបរលោកផង** ដែលហៅថា**និរាមិសសុខ** ។ ឯវិទ្យាសាស្ត្រ រកសេចក្ដីសុខនៅតែក្នុងលោកនេះតែម្យ៉ាង ដែលហៅថា **អាមិសសុខ** ។ **ដូច្នេះ គោលការពុទ្ធសាសនា និងវិទ្យាសាស្ត្រ ទាំងពីរនេះ ផ្សេងគ្នា** ។

មួយទៀត ធម៌ដែលអង្គព្រះសម្ពុទ្ធសម្ដែងប្រោសសត្វ ដោយពិតពុំមែនជាគ្រឿងតាំងទុកសម្រាប់លំអនៅក្នុងបណ្ណាល័យទេ ឬនឹងថាជាធម៌ ឬវិជ្ជាសម្រាប់សិក្សាបែបជាប្រវត្តិ-សាស្ត្រ បែបជាអក្សរសាស្ត្រក៏ពុំមែនដែរ ឬក៏នឹងថារក្សាទុកសម្រាប់អ្នកប្រាជ្ញ ឬពួកអ្នកបញ្ញវន្តទាំងឡាយក៏ទេដែរ ។ **ធម៌ព្រះអង្គជាធម៌សម្រាប់សិក្សាឲ្យចេះដឹង** ហៅថា **បរិយត្តិធម៌** “រៀនសូត្រឲ្យចេះដឹង” **រៀនសូត្រចេះដឹងហើយត្រូវប្រតិបត្តិតាម** ហៅថា **បដិបត្តិធម៌** “ធ្វើតាមធម៌ដែលបានរៀនសូត្រចេះដឹង” **បើបានប្រតិបត្តិត្រឹមត្រូវតាមគន្លងធម៌នេះហើយ នឹងបានផល** គឺការ **ត្រាស់ដឹង** “សម្មាសម្ពោធិញ្ញាណ” **ហើយបានសម្រេច** **មោក្ខធម៌** “ការរួចចាកទុក្ខទាំងពួង” ហៅថា **បដិវេធធម៌** “ការត្រាស់ដឹងធម៌” **បានសេចក្ដីថាធម៌ព្រះអង្គនេះសម្រាប់រៀនឲ្យចេះ ចេះហើយធ្វើតាម ធ្វើតាមហើយបានផលផ្លែផ្កា គឺសេចក្ដីសុខនៅក្នុងបច្ចុប្បន្នជាតិនេះផង និងជាដំណើរដើរទៅកាន់បរមសុខនៅក្នុងលោកុត្តរធម៌ផង** ។ អ្នកប្រតិបត្តិតាមធម៌ព្រះអង្គ ពិតជាបានសេចក្ដីសុខនៅនាលោកនេះផង ហើយពិតជាបានលុះទីបំផុតទុក្ខ ដែលយើងធុញទ្រាន់ជិនណាយនេះឥតសង្ស័យឡើយផង ព្រោះថាទីបំផុតទុក្ខនេះឯងហើយ ជាគោលដៅអវសានរបស់សត្វទាំងអស់ ។

ដូច្នេះ ធម៌ព្រះអង្គ ពុំមែនគ្រាន់តែល្អមើលទេ គឺទុកជាសំពៅភេត្រាសម្រាប់ជិះឆ្លងហើយចម្លងសត្វឲ្យឆ្លងផុតអន្លង់ទុក្ខ គឺមហាសាគរ ដែលហៅថា “**វាលវែងវដ្ដសង្សារ**” (ការអន្ទោលស្លាប់កើត) ។ **តាមទំនងនេះ ពុទ្ធសាសនា នឹងទុកដោយដាច់ខាតថាជាទស្សវិជ្ជា (Philosophie) ពុំបានឡើយ** ។



ព្រះមហាវិរិយបណ្ឌិតោ **ប៉ាង-ខាត់** សាស្ត្រាចារ្យខាងប្រវត្តិសាសនា

(១៩១០-១៩៧៥)

(រូបថតបានពីបណ្ឌិត ឃីង-ហុកឌី)

# ពុទ្ធសាសនាជាប្រព័ន្ធសីលធម៌ឬអ្វី?

សេចក្ដីពិត ពុំគួរមានសេចក្ដីសង្ស័យចំពោះពុទ្ធសាសនាទេ ។ **ពុទ្ធសាសនាពិតជាច្បាប់សីលធម៌** (Système éthique) **ដ៏ប្រសើរបំផុត ជាច្បាប់សមប្រតិបត្តិគ្រប់សម័យដោយប្រពៃ ប្រសើរលើសសីលធម៌ធម្មតាសកលលោកថែមទៀត** ។ សីលធម៌ដែលព្រះសម្ពុទ្ធសម្ដែងទូន្មានសត្វ ជាសីលធម៌ខ្ពស់ផុត ជាលំអខាងដើមនៃកុសលធម៌ទាំងពួង ជាមាគ៌ាដ៏ត្រង់ ដឹកនាំសត្វទៅកាន់ទីផុតទុក្ខដែលជាគោលដៅទីបំផុត ។ សីលធម៌ធម្មតាសកលលោក ជាច្បាប់សារ-វន្តពិតមែន តែពុំមែនជាច្បាប់ពេញលក្ខណៈបរិបូណ៌ក្នុងការដឹកនាំសត្វលោកឲ្យលុះឥស្សរភាព (liberté) បរិបូណ៌ ពោលគឺមោក្ខធម៌នោះឡើយ ។ សីលធម៌ធម្មតាសកលលោក បើនឹងមានប្រសិទ្ធិភាពពេញលេញ លុះត្រាតែប្រកបដោយបញ្ញានិងវិជ្ជាដទៃទៀតផង ទើបសមគួរនឹងបានទទួលនាមថាជាសីលធម៌ប្រសើរពិតមែន ។

ពុទ្ធសាសនាស្ដីពី **កម្ម** "អំពើ" (Action) គឺអំពើល្អ អាក្រក់ អព្យាក្រិត (កុសលកម្ម អកុ-សលកម្ម អព្យាកតកម្ម) ។ កម្មជាច្បាប់ធម្មជាតិ ពុំមែនជាច្បាប់តុលាការទេ ។ ច្បាប់តុលាការប្រកបដោយភ័យច្រើនណាស់ ។ សូមជ្រាបថា កម្ម ដែលស្ដីទុកក្នុងពុទ្ធសាសនា គឺកម្មមានចេតនា ។ **ចេតនាគឺសីល ចេតនាគឺកម្ម** ។ កម្មនេះពិតជាឲ្យផលវិបាកខ្លួនឯងពិត ព្រោះកម្មមានចេតនា។ ឯកម្មមិនមានចេតនា ពុំស្ដីទុកក្នុងពុទ្ធសាសនាទេ។ កម្មទាំងអស់ មានពលានុភាពក្នុងខ្លួនឯង ហើយធ្វើការជានិច្ចក្នុងខ្លួនឯង ចូរមើលចលនាមហាភូតរូបចុះ ធ្វើការក្នុងខ្លួនជានិច្ច ។ ដូច្នេះ **កម្ម** គឺ **អ្នកនិមិត្ត** ឬ **ស្ថាបនិក** (Architecte) សាងអ្វីៗទាំងអស់ក្នុងលោក ។ បើ **អា-ទិទេពព្រហ្មនី** ឬ **តេ៎** មានអត្ថន័យថា " **កម្ម** " វិញ នុ៎ះមានសេចក្ដីប្រសើរណាស់ ។ **គួរសាធុ-ជន ពោលថា ពុទ្ធសាសនានេះ ជា លិទ្ធិកម្មនិយម** (លទ្ធិស្ដីពីកម្ម) បានដោយបរិបូណ៌ ។ បណ្ដាកម្ម៣ប្រការខាងដើម អំពើល្អ (កុសលកម្ម) ជាអំពើសារវន្តបំផុត ក្នុងការកសាងខ្លួនបុគ្គលម្នាក់ៗឲ្យបានជាបុគ្គលប្រសើរ ហើយឲ្យរួចចាកទុក្ខគ្រប់ប្រការ ដោយការបំពេញព្រហ្ម-ចរិយធម៌បរិបូណ៌ ដូចមានសេចក្ដីក្នុងគម្ពីរមជ្ឈិមនិកាយ ដែលអង្គព្រះសម្ពុទ្ធត្រាស់ថា៖

**"ព្រះធម៌ (កុសលធម៌) ដែលបុគ្គលម្នាក់ៗបានចម្រើនហើយ បានធ្វើឲ្យមានច្រើន ច្រើនហើយ ច្រើនទាល់តែលើសលប់ អាចកន្លងបង់នូវអធម៌ (អកុសលធម៌) ទាំងអស់បានពិតប្រាកដ"** ។

**កម្ម**(អំពី)នៃព្រះអរហន្តជាខីណាស្រេព ពុំមែនជាកុសលឬអកុសលទេ ព្រោះសន្តានចិត្តរបស់លោក បានកន្លងផុតធម៌ទាំងពីរប្រការនេះអស់ហើយ ។ តែសេចក្ដីនេះ ពុំមែនមានន័យថា "ព្រះអរហន្តអស់ការងារទេ" ពោលគឺមិនមានសេចក្ដីថា "ព្រះអរហន្តនៅស្ងៀមព្រងើយកន្តើយ" (passive) (១) ឡើយ ដោយពិត ព្រះអរហន្តជាអ្នកសកម្ម (Active) ប្រសើរលើសជន

-------------------------

(១) He is passive.

សាមញ្ញទៅទៀត តែសកម្មភាពរបស់លោក ជាសកម្មភាពឥតវិបាក ដែលហៅថា “កិរិយា” (១) ហើយជាសកម្មភាពដឹកនាំសត្វឲ្យដើរទៅតាមមាគ៌ាដ៏ប្រសើរ ដែលលោកបានត្រាស់ដឹងពិតតាមពិត ឆ្ពោះទៅកាន់សិវដ្ឋានក្សេមក្សាន្តនិរទុក្ខនិរភ័យ ។ សកម្មភាពរបស់លោក តាមធម្មតាជាអំពើកុសល ជាអំពើមានអានុភាពខ្លាំង ដឹកនាំសត្វលោកឲ្យបានសម្រេចប្រយោជន៍, ឧបមាដូចមាស មាសដែលជាងមាសដេញឲ្យអស់មន្ទិលហើយ ជាវត្ថុធាតុបរិសុទ្ធមិនបាច់ដេញទៅទៀតយ៉ាងណា ព្រះអរហន្តជាវត្ថុធាតុបរិសុទ្ធ មិនមានករណីយកិច្ចដែលជាកម្មវិបាកតទៅទៀតទេ យ៉ាងនោះដែរ ។ ព្រះអរហន្តយល់ច្បាស់ធម៌ ចាក់ធ្លុះធម៌ពិតតាមពិតដោយពិត ត្រាស់ដឹងធម៌ ជាធម៌មានភាពបំផ្លាញបង់នូវសង្សារចក្រ ពោលគឺបដិច្ចសមុប្បាទធម៌ “ធម៌ជាច្បាប់ហេតុផល” ។

សេចក្តីដូចបានពោលមកនេះ គួរលើកមកបញ្ជាក់ម្តងទៀតថា “លក្ខណៈអ្វីជាអាទិទេពដែលថាមានអានុភាពលើអ្វីទាំងអស់ ឬអ្វីដទៃទៀតដែលជាភាពតំណាងអាទិទេពមានឫទ្ធានុភាពនោះ ពុំមានចំណែកណាមួយទាល់តែសោះនៅក្នុងពុទ្ធសាសនា” ។ ក្នុងពុទ្ធសាសនា ពុំមានអ្នកណាមួយជាអ្នកចាំប្រទានរង្វាន់ ឬជាអ្នកចាំដាក់បណ្តាសាឲ្យមានបាបនោះទេ ។ **សុខក្តីទុក្ខក្តី សុទ្ធតែជាផលដែលចេញមកពីកម្ម “អំពើ” របស់ខ្លួនគ្រប់គ្នាទាំងអស់** ។ គំនិតដែលគិតថា ទេពតាពេញព្រះទ័យ ហើយប្រោសប្រទានរង្វាន់ក្តី ឬទេពតាមិនសព្វព្រះទ័យហើយក្រេវក្រោធដាក់បណ្តាសាឲ្យមានបាបក្តី ពុំមាននៅក្នុងសន្តានចិត្តពុទ្ធសាសនិកជនទេ សូម្បីតែក្តីសង្ឃឹមថា ទេពតានឹងប្រោសប្រទានរង្វាន់ក្តី ឬក្តីបារម្ភថា ទេពតានឹងដាក់បណ្តាសាក្តី ក៏ពុំមានដែរ ។ ពុទ្ធសាសនិកជន ដឹងខ្លួនចំពោះវិបាករបស់ខ្លួនក្នុងអនាគតកាលជានិច្ច៖

-មានសតិសម្បជញ្ញៈ តាំងចិត្តវៀរអំពើអាក្រក់ដោយកាយ វាចា ចិត្ត ព្រោះយល់ច្បាស់ថា អំពើអាក្រក់ជាផលអាក្រក់ នាំឲ្យរងទុក្ខវេទនានៅនាលោកនេះ និងបរលោក ហើយជាហេតុនាំពន្យឺតដំណើរ មិនឲ្យសម្រេចនិព្វានឆាប់;

-តាំងចិត្តបំពេញកុសលធម៌ ព្រោះយល់ច្បាស់ថា អំពើល្អជួយស្រោចស្រង់ខ្លួនឲ្យបានក្តីសុខនៅនាលោកនេះ និងបរលោក ហើយនាំខ្លួនឲ្យខិតចូលទៅជិតសម្មាសម្ពោធិញ្ញាណ “ការត្រាស់ដឹង” ដែលជាគោលបំណងអវសានបំផុត ។

ដើម្បីយល់ច្បាស់នូវសីលធម៌ដ៏ខ្ពង់ខ្ពស់នេះ សូមអស់លោក, អ្នកទាំងឡាយ អញ្ជើញមើលពុទ្ធភាសិតនានា ដែលមាននៅក្នុងសូត្រទាំងឡាយ មានធម្មបទ សិគាលោវាទសូត្រ ព្យគ្ឃបជ្ជសូត្រ មង្គលសូត្រ ករណីយសូត្រ បរាភវសូត្រ វសលសូត្រ ធម្មិកសូត្រ ជាដើមទៀតចុះ ។ ដូច្នេះ ពុទ្ធសាសនានេះ បើមើលតាមអត្ថន័យមួយបែប ពុំមែនត្រឹមតែជាទស្សនវិជ្ជាប៉ុណ្ណឹងទេ បើមើលតាមអត្ថន័យមួយបែបទៀត **ជាទស្សនវិជ្ជាលើទស្សនវិជ្ជា**ទាំងឡាយទៅទៀត ។ ពុទ្ធសាសនានេះ បើមើលតាមអត្ថន័យមួយបែបពុំមែនត្រឹមតែជាលទ្ធិសាសនា (Religions) ទេ បើមើលតាមអត្ថន័យមួយបែបទៀត **ជាលទ្ធិសាសនាលើលទ្ធិសាសនាទាំង**

-------------------

(១) កិរិយាដែលធ្វើ មិនឲ្យផលជាល្អជាអាក្រក់ ។

ឡាយ ។ ពុទ្ធសាសនា បើនិយាយពីសីលធម៌ **ជាសីលធម៌ប្រសើរលើសលើវិធីសីលធម៌ទាំងឡាយ** ។ វីសីលធម៌នេះទៀត ពិតជាខាងដើមនៃសេចក្តីល្អ (កុសលធម៌) ទាំងឡាយ ហើយសូមជ្រាបថា ពុំមែនជានៅចុងប៉ូចនៃពុទ្ធសាសនាទេ ។

ពាក្យថា “**ពុទ្ធសាសនា**” បើតាមអត្ថន័យជាភាសាបាលី ដែលជាសំណៅដើម លោកប្រើពាក្យថា “**ធម្ម**” ជាពាក្យដែលលោកលើកយកមកប្រើសម្រាប់ហៅ “**ពុទ្ធសាសនា**” ។ ពាក្យថា “**ធម្ម**” មិនមានអត្ថន័យក្នុងភាសាដទៃណាមួយឲ្យមានសំនួនវោហារប៉ុនគ្នាឡើយ ។ ឯពាក្យថា “**ធម្ម**” នេះ មានប្រាកដការនិយម ពោលគឺជាវាទៈដែលស្តីពីសច្ចធម៌ ជាធម៌ពិតដ៏ប្រសើរ ដឹកនាំសត្វទៅកាន់សេរីភាព ទៅកាន់ការរួចស្រឡះ = មោក្ខធម៌ (ការរួចស្រឡះដោយខ្លួនឯង) ។ ធម៌នេះ ទោះយោបីព្រះសម្ពុទ្ធកើតឡើងក្តី មិនកើតឡើងក្តី តែងតែជាធម៌ប្រាកដការនិយមជាប្រក្រតី ។ **ព្រះសម្ពុទ្ធ គ្រាន់ជាអ្នកបើកធម៌នេះ បង្ហាញឲ្យមើលឃើញប្រត្យក្ស ដូចជាបើកគំរបដែលគ្របលាក់វត្ថុអ្វីមួយឲ្យមើលឃើញតែប៉ុណ្ណោះទេ ព្រោះថាធម៌នេះកប់បាត់ក្នុងអវិជ្ជាធម៌របស់មនុស្សទាំងឡាយ លុះព្រះអង្គបានត្រាស់ដឹងធម៌ហើយ ទើបទ្រង់ប្រកាសធម៌នេះឡើងដល់មនុស្ស ទេពតាព្រហ្មទាំងឡាយ** ដោយករុណាធម៌របស់ព្រះអង្គ ។ បើប្រៀបធៀបជាសេចក្តីឲ្យឃើញពិត ធម៌នេះជាធម៌រតនវត្ថុ ដូចពេជ្រកប់នៅក្នុងភ្នំគឺអវិជ្ជា **ព្រះពុទ្ធទ្រង់ជាអ្នកឃើញធម៌គឺពេជ្រនេះ ហើយគាស់កកាយយកមកបង្ហាញសត្វទាំងឡាយ** ថា “**នេះធម៌នាំអ្នកទាំងឡាយទៅកាន់ឥស្សរភាព (មោក្ខធម៌) ផុតអន្លង់ទុក្ខគ្រប់ប្រការ**” ។

ដូច្នេះ សាធុជនទាំងឡាយ ជាអ្នកស្រឡាញ់ខ្លួន គួរប្រតិបត្តិតាមពុទ្ធសាសនានេះចុះ អស់លោកអ្នក នឹងបានក្តីសុខសមតាមប្រាថ្នាពុំខានឡើយ ។

